# របាយការណ៍លទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣
# របស់អភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

## សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យ ស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណជា ៤៤៧ គ.ម ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦,៨៤០.៩៦ គ.ម២។ មានព្រំប្រទល់ខាងកើតជាប់ខេត្តព្រះវិហារ ខាងលិចជាប់ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់ខេត្តសៀមរាប និងខាងជើងប្រវែង ២២៤ គ.ម ជាប់ខេត្តស៊ីសាកេត ខេត្តបុរីរាំង និងខេត្តសុរិនប្រទេសថៃ។ ខេត្តមានស្រុកចំនួន ៤ និងក្រុង ១ គឺស្រុកអន្លង់វែង ត្រពាំងប្រាសាទ ចុងកាល់ បន្ទាយអំពិល និងក្រុងសំរោង មានឃុំចំនួន ១៩ សង្កាត់ចំនួន ៥ និងភូមិចំនួន៣០៤ភូមិ មានប្រជាពលរដ្ឋចំនួន៥៧ ២៣៩ គ្រួសារ និងមានប្រជាជនសរុប២៤១,៩៨៦ នាក់។ ខេត្តឧត្តរមានជ័យ មានប្រជាជនប្រមាណជា ៨០ ភាគរយ ជាកសិករ ៨ ភាគរយ ជាអាជីវករ និង ១២ ភាគរយ ជាមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ។

ក្នុងរយៈពេល០១ឆ្នាំ (២០២២) នេះ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ បានទទួលការគាំទ្រពីក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍនានាសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋានដោយសម្រេចបានលទ្ធផលជាច្រើនដូចខាងក្រោម៖

## I. សមិទ្ធផលសម្រេចបាន

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

#### ក.ការងាររដ្ឋបាល និងបុគ្គលិក

គិតត្រឹមខែធ្នូ ឆ្នាំ២០២២ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ មានមន្ត្រីរាជការសរុបចំនួន ២០រូប ស្ត្រីចំនួន០១រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន ០១រូប រួមមាន៖ ប្រធានមន្ទីរ ០១រូប អនុប្រធានមន្ទីរ ០៣រូប ប្រធានការិយាល័យថ្នាក់មន្ទីរចំនួន ០៩រូប អនុប្រធានការិយាល័យថ្នាក់មន្ទីរចំនួន ០៦រូប មន្ត្រីការិយាល័យថ្នាក់មន្ទីរចំនួន ០១រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន០១រូប ក្នុងនោះមានមន្ត្រីរាជការ ០១រូប ចូលនិវត្តន៍។ មន្ទីរបានចេញលិខិតទៅបណ្តាអង្គភាពនានាចំនួន ១៥៧ លិខិត លិខិតពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន ១៥៨ លិខិត លិខិតចេញទូទៅ ចំនួន ១២ លិខិត និងលិខិតចេញទៅក្រសួង និងបណ្តាអង្គភាពនានាក្រោមឱវាទមន្ទីរ ចំនួន ៥០ លិខិត។

មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ បានអនុវត្តន៍ការចុះវត្តមានរបស់មន្ត្រីជាប្រចាំថ្ងៃ និងបានរៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងវត្តមានប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំជូននាយកដ្ឋានរដ្ឋបាល និងបុគ្គលិកបានទាន់ពេលវេលា និងមានការទទួលខុសត្រូវ។

## ខ. ការងារផែនការ

- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ ផ្ញើទៅក្រសួងអភិវឌ្ឍន៍ជនបទ
- បានរៀបចំផែនការថវិកាឆ្នាំ២០២៣
- បានរៀបចំកសាងផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ឆ្នាំ២០២៣-២០២៥
- បានរៀបចំបូកសរុប និងផ្ញើរបាយការណ៍ស្តីពីវឌ្ឍនភាពរយៈពេល០៥ឆ្នាំរបស់មន្ទីរ
- បានបូកសរុប និងផ្ញើរបាយការណ៍ស្តីពីវឌ្ឍនភាពរបស់មន្ទីរ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំបានទៀងទាត់។

## គ. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

| ជំពូក | បរិយាយ សកម្មភាព | ស្ថានភាពឥណទាន | ចំណាយឥណទាន | សមតុល្យ |
|---|---|---|---|---|
| ៦០ | ការទិញ | ១២៨,៩០០,០០០ | ១១៨,០៤៩,៧០០ | ៩,៩៥០,៣០០ |
| ៦១ | សេវាខាងក្រៅ | ១,៣៥៧,៩០០,០០០ | ១,៣៣៤,៦៣២,០០០ | ២៣,២៦៨,០០០ |
| ៦៣ | ពន្ធ និងអាករ | ៦,០០០,០០០ | ១,៦០០,០០០ | ៤,៤០០,០០០ |
| ៦៤ | បន្ទុកបុគ្គលិក | ៣៩៦,៧០០,០០០ | ៣៥៧,៦២៧,៥០០ | ៣៩,០៧២,៥០០ |
| សរុបរួម | | ១,៨៨៨,៦០០,០០០ | ១,៨១១,៩០៩,២០០ | ៧៦,៦៩០,៨០០ |

- បានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះរបស់មន្ទីរអភិវឌ្ឍន៍ជនទខេត្តឧត្តរមានជ័យ សម្រាប់ឆ្នាំ២០២២
- ធ្វើរបាយការណ៍ចំណូល ចំណាយប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បានបង្វែប្រាក់បៀវត្ស និងប្រាក់បេសកកម្មរបស់មន្ត្រីរាជការទៅតាមប្រព័ន្ធធនាគារ
- បានធ្វើរបាយការណ៍បើកប្រាក់បៀវត្សរបស់មន្ត្រីរាជការក្នុងមន្ទីរប្រចាំខែ ទៅក្រសួងបានទាន់ពេលវេលា។

## ង. ការងារសវនកម្ម

- ក្រុមការងារសវនកម្មបានចុះធ្វើអធិការកិច្ចលើការគ្រប់គ្រង និងការអនុវត្តន៍ចំណូលចំណាយថវិការដ្ឋ ថវិការបើកផ្តល់ពីក្រសួងសាមី ថវិការបដិភាគ និងកាគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ រួមមាន៖
  - គណៈប្រតិភូ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - គណៈប្រតិភូ អាជ្ញាធរសវនកម្មជាតិ
  - គណៈប្រតិភូ សវនកម្មលទ្ធកម្ម
  - សវនកម្មផ្ទក្នុងក្រសួងអភិវឌ្ឍន៍ជនបទ។

# ២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍

## ក.ការងារថែទាំផ្លូវជនបទ និងសំណង់សិល្បការ្យ

- ជួសជុលផ្លូវថែទាំលក្ខណៈខួបចំនួន០២ខ្សែ ប្រវែង ២៤.២ គ.ម នៅភូមិគោល ឃុំក្រសាំង ស្រុកចុងកាល់ និងឃុំលំទង ស្រុកអន្លង់វែង សម្រេចលទ្ធផលបាន១០០%។

- ជួសជុលផ្លូវក្រាលគ្រួសក្រហមអន្តរាគមន៍បន្ទាន់ ចំនួន០២ខ្សែ ប្រវែង ៤.៥ គ.ម ស្ថិតនៅក្រុងសំរោង និងស្រុកចុងកាល់ សម្រេចបានលទ្ធផលបាន១០០%។
- ជួសជុលផ្លូវក្រាលគ្រួសក្រហមថែទាំប្រចាំចំនួន ១៣ ខ្សែ ប្រវែង ១២៣.២ គ.ម ស្ថិតនៅក្រុងសំរោង ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ សម្រេចបានលទ្ធផលបាន១០០%។

**ខ. ការងារជួសជុលផ្លូវជនបទ និងសំណង់សិល្បការ្យ**

- ជួសជុលផ្លូវក្រាលគ្រួសក្រហមចំនួន០១ខ្សែ ប្រវែង ១២គ.ម នៅភូមិពោធិ៍ចាស់ដល់ភូមិសំរោងទា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ លទ្ធផលសម្រេចបាន១០០%។

## ៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

**ក.ការងារសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ**

- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវ (Afridev) បានចំនួន ១២ អណ្តូង ស្ថិតនៅ ក្រុងសំរោង និងស្រុកចុងកាល់ សម្រេចលទ្ធផលបាន១០០%។

**ខ. ការងារសាងសង់បង្គន់អនាម័យជនបទ**

- បានឧបត្ថម្ភធនផ្តល់សម្ភារៈបង្គន់អនាម័យជូនគ្រួសារក្រីក្រ ចំនួន១៨៣ បង្គន់ ស្ថិតនៅឃុំចុងកាល់ ស្រុកចុងកាល់ សម្រេចលទ្ធផល១០០%។
- បានឧបត្ថម្ភធនផ្តល់សម្ភារៈបដិភាគបង្គន់អនាម័យ ជូនគ្រួសារក្រីក្រចំនួន ៥០ បង្គន់ នៅភូមិកំណប់ សង្កាត់បន្សាយរាក់ ក្រុងសំរោង សម្រេចលទ្ធផល១០០%។

**គ.ការងារអភិវឌ្ឍន៍សហគមន៍ជនបទ**

- ចុះបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ស្តីពីផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ ចំនួន០៣វគ្គ នៅឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

## ៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

**ក.ការងារលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- ប្រមូលប្រាក់កម្ចីបង់រំលោះសម្រាប់មន្ត្រីរាជការចំនួន ០៧ រូប ប្រចាំខែ ជូនទៅមន្ទីរអភិវឌ្ឍន៍ជនខេត្តត្បូងឃ្មុំ។

**ខ.ការងារអភិវឌ្ឍន៍សហគមន៍**

- ការិយាល័យអភិវឌ្ឍន៍សហគមន៍ បានចុះបើកវគ្គបណ្តុះបណ្តាលស្តីពីការកសាងផែនការអភិវឌ្ឍន៍ភូមិ ដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ចំនួន០២វគ្គ មានសិការកាមចូលរួមសរុបចំនួន៤០នាក់ ស្រី១៦ នាក់ នៅឃុំបេង ស្រុកបន្ទាយអំពិល។

## ៥.សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ

**ក. ការងារសហប្រតិបត្តិការជាមួយគម្រោងដៃគូរអន្តរជាតិ**

- គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទដំហាន៣ មានដូចខាងក្រោម៖
  - សាងសង់អណ្តូងស្នប់ចំនួន៩៥អណ្តូង នៅឃុំអំពិល ស្រុកបន្ទាយអំពិល សម្រេចលទ្ធផល ១០០%។

- សាងសង់ស្រះសហគមន៍ចំនួន០៨ ស្រះ នៅឃុំអំពិល ស្រុកបន្ទាយអំពិល សម្រេចលទ្ធផលបាន១០០%។
- សាងសង់អាងត្រងទឹកភ្លៀងចំនួន០៩ អាង នៅឃុំអំពិល ស្រុកបន្ទាយអំពិល សម្រេចលទ្ធផល បាន១០០%។
- សាងសង់បង្គន់តាមគ្រួសារក្រីក្រ ចំនួន២៥៩បង្គន់ នៅឃុំអំពិល ស្រុកបន្ទាយអំពិល សម្រេចលទ្ធផល បាន១០០%។
- ផ្តល់ពាងត្រងទឹកភ្លៀង ចំនួន៧៦ពាង នៅឃុំអំពិល ស្រុកបន្ទាយអំពិល សម្រេចលទ្ធផលបាន១០០%។

## II. បញ្ហាប្រឈម

- ប្រជាជនបទពុំទាន់ប្រតិបត្តិបានល្អនៅឡើយលើការថែទាំសុខភាពអនាម័យ
- ប្រជាជនបទក្រីក្រមួយចំនួនពុំទាន់មានបង្គន់អនាម័យប្រើប្រាស់
- ប្រជាជនបទពុំទាន់មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ ពុំទាន់ឆ្លើយតបបានតាមតំរូវការចាំបាច់នៅមូលដ្ឋាន
- សមត្ថភាពជំនាញ បទពិសោធន៍ និងចំណេះដឹងរបស់មន្ត្រីរាជការរបស់មន្ទីរមួយចំនួននូវមានកម្រិត មិនទាន់បានឆ្លើយតបទៅនឹងកំណែទម្រង់លើគ្រប់វិស័យអភិវឌ្ឍន៍ជនបទ
- ខ្វះមន្ត្រីបំពេញការងារ
- ស្ថានភាពរីករាលដាលនៃជម្ងឺកូវីដ១៩ បានបង្អាក់ល្បឿនដល់ការងារអភិវឌ្ឍន៍នៅតំបន់ជនបទ។

## III. ទិសដៅការងារឆ្នាំ២០២២

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

#### ក. ការងាររដ្ឋបាល និងបុគ្គលិក

- វត្តមានជាប្រចាំថ្ងៃ និងមានវិធានការច្បាស់លាស់ចំពោះមន្ត្រីដែលអវត្តមាន
- រៀបចំ និងទុកដាក់ឯកសារក្នុងការិយាល័យរដ្ឋបាលឱ្យមានរបៀបរាបរយ និងងាយស្រួល
- ពិនិត្យការដំឡើងថ្នាក់ជូនមន្ត្រីរាជការស្របតាមគោលការណ៍ណែនាំរបស់ក្រសួង
- បន្តរៀបចំការលើកទុកចិត្តមន្ត្រីតាមរយៈការផ្តល់តួនាទី និងគ្រឿងឥស្សរិយយសប្រចាំឆ្នាំចំពោះមន្ត្រីរាជការណាដែលបានខិតខំ និងអនុវត្តតួនាទីភារកិច្ចល្អជាងគេ

#### ខ. ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយ ដល់មន្ត្រីរាជការ

- បន្តរៀបចំរបាយការណ៍បណ្តុះបណ្តាល និងសិក្ខាសាលាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ទៅនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ។

#### គ. ការងារផែនការ

- បន្តចូលរួមរៀបចំផែនការ និងតាមដានការអនុវត្តផែនការអោយមានប្រសិទ្ធភាព
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ ២០២៤-២០២៦
- បានរៀបចំផែនការថវិកាឆ្នាំ២០២៤ ផ្ញើទៅក្រសួងអភិវឌ្ឍន៍ជនបទ

- បន្តរៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពរបស់មន្ទីរស្តីពីការអនុវត្តសកម្មភាព ជាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- បន្តការរៀបចំផែនការវិនិយោគបីឆ្នាំរំកិលជូនរដ្ឋបាលខេត្តឧត្តរមានជ័យ។

**ឃ. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

- បន្តរៀបចំ និងសម្របសម្រួលជំពូកថវិកា និងរាល់ការចំណាយរបស់មន្ទីរអោយមានប្រសិទ្ធភាពខ្ពស់ និងការទទួលខុសត្រូវ
- បន្តត្រួតពិនិត្យបញ្ជីចំណូលចំណាយត្រឹមត្រូវតាមទម្រង់បែបបទគណនេយ្យ
- បន្តលើកគម្រោងថវិការបស់មន្ទីរ ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិការ
- បន្តផ្គត់ផ្គង់ផ្នែកសំភារៈជូនដល់បណ្តាការិយាល័យចំណុះមន្ទីរ
- បន្តគ្រប់គ្រងបែងចែកសំភារៈ និងមធ្យោបាយដឹកជញ្ជូន
- បន្តរៀបចំសំណើថវិកា និងរបាយការណ៍ចំណូលចំណាយ
- បន្តគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- បន្តធ្វើកម្មវិធីបែងចែកថវិកា ប្រេងឥន្ទនៈ គ្រឿងបន្លាស់សម្រាប់យានយន្តរបស់រដ្ឋ
- បន្តគ្រប់គ្រងជួសជុលសម្ភារៈ និងបរិក្ខាររបស់មន្ទីរ។

## ២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍

**ក. ការងារថែទាំផ្លូវជនបទ និងសំណង់សិល្បការ្យ**

- បន្តជួសជុលផ្លូវក្រាលគ្រួសក្រហមចំនួន ០១ខ្សែ មានប្រវែង ១២ គ.ម នៅបាត់ថ្កៅ ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។

## ៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

**ក. ការងារសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ**

- បន្តសាងសង់អណ្តូងស្នប់អាហ្វ្រីដេវ (Afridev) ចំនួន អណ្តូ០៩ អណ្តូង នៅស្រុកចុងកាល ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ។

**ខ. ការងារសាងសង់ និងស្តារប្រព័ន្ធស្រោចស្រពខ្នាតតូច**

- បន្តសាងសង់ស្រះសហគមន៍០១កន្លែង នៅភូមិមនោរម្យសែនជ័យ ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

**គ. ការងារសាងសង់បង្គន់អនាម័យជនបទ**

- បានឧបត្ថម្ភធនផ្តល់សម្ភារៈបង្គន់អនាម័យជូនគ្រួសារក្រីក្រ ចំនួន១៩០ បង្គន់ ស្ថិតនៅឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

## ៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

**ក. ការងារលើកកម្ពស់ និងបង្កើតមុខរបរនៅជនបទ**

- បន្តចុះសិក្សាទីតាំងភូមិសាស្ត្រដើម្បីរៀបចំសំណើគម្រោងសាងសង់ផ្សារជនបទ
- បន្តធ្វើកិច្ចសហការល្អជាមួយស្ថាប័ន អង្គការដៃគូអោយបានល្អ លើការងារលើកកម្ពស់ និងជួយរកទីផ្សារជូនប្រជាពលរដ្ឋ។

### ខ. ការងារអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច

- បន្តចុះស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពចំនួនជនជាតិដើមភាគតិចនៅតាមភូមិ ឃុំ
- បន្តខិតខំស្វែងរកការគាំទ្រអង្គការដៃគូ ដើម្បីការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច។

## ៥.សមិទ្ធិផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ

### ក. ការងារសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងអង្គការដៃគូរជាតិ

- បន្តធ្វើកិច្ចសហការល្អជាមួយអង្គការ Samaritan's Puse អង្គការ Fh Cambodia អង្គការទឹកស្អាត ១០០១ និងខិតខំពង្រីកការទំនាក់ទំនងទៅអង្គការផ្សេងៗដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍន៍មូលដ្ឋាន។

### ខ. ការងារសហប្រតិបត្តិការជាមួយគម្រោងដៃគូរអន្តរជាតិ

- ខិតខំបន្តការស្វែងរកអង្គការដៃគូអន្តរជាតិដើម្បីជួយគាំទ្រដល់ការស្ថាបនាផ្លូវជនបទ ការងារលើកកម្ពស់អនាម័យជនបទ ការងារផ្គត់ផ្គង់ទឹកជនបទ និងការផ្សេងៗទៀតដែលទាក់ទងនឹងវិស័យអភិវឌ្ឍន៍ជនបទ។

## IV.សេចក្តីសន្និដ្ឋាន

មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ បង្កើនការយកចិត្តទុកដាក់បំពេញការងារប្រកបដោយជោគជ័យតាមផែនការដែលបានគ្រោង និងបាននាំមកនូវការប្រែប្រួលជាវិជ្ជមាន អំពីស្ថានភាពជីវភាពរស់នៅដោយសុខដុមមនោរបស់បងប្អូនប្រជាពលរដ្ឋនៅជនបទ រួមមានសមិទ្ធផលជាច្រើនដែលរាជរដ្ឋាភិបាលផ្តល់ជូនតាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ ជូនមន្ទីរអភិវឌ្ឍន៍ជនបទ ដើម្បីអភិវឌ្ឍន៍នៅមូលដ្ឋានដូចជា៖ ផ្លូវជនបទ ស្ពាន លូគ្រប់ប្រភេទ ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ អប់រំសុខភាពអនាម័យ ការផ្គត់ផ្គង់ទឹកស្អាត ដែលជាគ្រឹះដ៏មានសារៈសំខាន់បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ រស់នៅប្រកបដោយសុខដុមរមនា និងសុភមង្គល។

ក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយការយកចិត្តទុកដាក់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងការជួយគាំទ្រទាំងផ្នែកបច្ចេកទេសពីថ្នាក់ដឹកនាំក្រសួង នាយកដ្ឋានជំនាញ ថ្នាក់ដឹកនាំខេត្ត ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីរាជការនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ធ្វើឲ្យផែនការថវិកាឆ្នាំ២០២៣ ដែលត្រូវបានរៀបចំឡើងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីគ្រប់ជំនាញ ក្រោមឱវាទបន្តខិតខំប្រឹងប្រែងយកចិត្តទុកដាក់រួមសហប្រតិបត្តិការ ជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាពតាមតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីរួមចំណែកកសាងមូលដ្ឋានគ្រឹះសង្គមជនបទស៊ីវិល័យនៅពេលអនាគតខាងមុខស្របតាមគោលនយបាលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជាការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

លទ្ធផលយ៉ាងច្រើនក្នុងឆ្នាំ២០២២នេះ គឺពិតជាការឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់ពីការយកចិត្តទុកដាក់ខ្ពស់ និងផ្តល់អនុសាសន៍ដឹកនាំល្អៗពីថ្នាក់ដឹកនាំក្រសួង ក្រោមការដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងមានការដឹកនាំ និងសម្របសម្រួលផ្ទាល់ពីលោកប្រធានមន្ទីរ ថ្នាក់ដឹកនាំមន្ទីរ ប្រកដោយដោយការទទួលខុសត្រូវខ្ពស់។ ដូច្នេះមន្ទីរអភិវឌ្ឍន៍

ជនបទខេត្តឧត្តរមានជ័យ នឹងបន្តខិតខំព្យាយាមបន្ថែមទៀតចំពោះផែនការដែលបានដាក់ចេញសម្រាប់អនុវត្តការងារក្នុងឆ្នាំ២០២៣ អោយមានប្រសិទ្ធភាពខ្ពស់ និងការទទួលខុសត្រូវ៕

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័កព.ស.២៥៦៦

ខេត្តឧត្តរមានជ័យ, ថ្ងៃទី ខែ ឆ្នាំ២០២២

**ប្រធានមន្ទីរ**